មជ្ឈមណ្ឌលជាតិនៃជនពិការ

មជជព

NCDP

National Centre of Disabled Persons

# គោលការណ៍ផ្ទេរសកម្មភាព

## របស់កម្មវិធី/គ្រោងការនៃ មជជព

ខែ តុលា ឆ្នាំ ២០០៨

- យោងលក្ខន្តិកៈ និងសេចក្តីប្រកាសបង្កើត **មជជព** លេខ ៧៥៧ ស.ក.អ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៧
- យោងតាមផែនការយុទ្ធសាស្ត្រ ៥ ឆ្នាំ (២០០៨-២០១២) របស់ **មជជព** ដែលបានប្រព្រឹត្តទៅនៅខេត្តស្ទឹងត្រែង នាថ្ងៃទី ១០-១២ ខែ កក្កដា ឆ្នាំ ២០០៧
- កិច្ចប្រជុំបច្ចេកទេសនៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៨ របស់គណៈគ្រប់គ្រង **មជជព** បានសំរេចៈ
    - គ្រប់កម្មវិធី/គ្រោងការទាំងអស់ ដែលមានសកម្មភាពនៅតាមសហគមន៍ ត្រូវមានគោលការណ៍ផ្ទេរសកម្មភាព ដើម្បីទៅបង្កើតសកម្មភាពការងារនៅតំបន់ដទៃទៀត ដែលមានជនពិការកំពុងរង់ចាំសេវាកម្មពី **មជជព**
    - មជជព ត្រូវបង្កើតឱ្យមានគោលការណ៍ផ្ទេរសកម្មភាពមួយ សំរាប់កម្មវិធី/គ្រោងការទាំងអស់ យកទៅអនុវត្តឱ្យមាន ប្រសិទ្ធភាព និងប្រសិទ្ធផល

# គោលការណ៍

**ប្រការ ១:** មជជព សំរេចបង្កើតគោលការណ៍ផ្ទេរសកម្មភាព របស់កម្មវិធី/គ្រោងការ ក្នុងគោលបំណងៈ

- ផ្ទេរចំណេះដឹង និងចំណេះធ្វើ ដល់ជនពិការ មន្ត្រីដែលពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន នូវសកម្មភាពអភិវឌ្ឍន៍សហគមន៍ដែលទាក់ទងនិងវិស័យពិការភាព ។
- ឱ្យជនពិការបានទទួលនូវស្ថេរភាពសេវាកម្ម មានជីវភាពរស់នៅកាន់តែប្រសើរឡើង និងទទួលសេវាកម្មប្រកបដោយ សុច្ចរិត យុត្តិធម៌ មានគុណតម្លៃ ដោយគោរពសិទ្ធិរបស់ជនពិការជាមូលដ្ឋាន ។
- អនុញ្ញាតប្រើប្រាស់សម្រាប់កម្មវិធី និងគ្រោងការរបស់ **មជជព** ដែលកំពុងបម្រើផលប្រយោជន៍ឱ្យជនពិការរស់នៅក្នុងសហគមន៍។ ធ្វើយ៉ាងនេះ ដើម្បីឱ្យ **មជជព** និងអ្នកទទួលផលបានសម្រេចសិមិទ្ធិផល និងទទួលយកប្រកបដោយនិរន្តរភាព ។

## ជំពូក ១

## ដំណើរការ និងនីតិវិធី

**ប្រការ ២:** រយៈពេលកំណត់ និងគោលបំណងឆ្នាំនីមួយៗ

គ្រប់កម្មវិធី/គ្រោងការរបស់ **មជជព** ត្រូវអនុវត្តន៍ សកម្មភាពក្នុងតំបន់នោះ ឱ្យបានយ៉ាងតិចពី ៣-៥ ឆ្នាំ។

ឆ្នាំទី ១:

- ផ្សព្វផ្សាយពី **មជជព ខ**
- ផ្សព្វផ្សាយពី សកម្មភាពការងាររបស់ កម្មវិធី/គ្រោងការ ដែលត្រូវចុះអនុវត្តន៍ ។
- រៀបចំអនុសារណៈដើម្បីមានរចនាសម្ព័ន្ធអនុវត្តសកម្មភាពរបស់ កម្មវិធី/គ្រោងការ ឱ្យមាននិរន្តរភាព ។
- កម្មវិធី/គ្រោងការរបស់ **មជជព** អនុវត្តន៍សកម្មភាពជាបណ្ដើរៗ ។

ឆ្នាំទី ២:

- កម្មវិធី/គ្រោងការរបស់ **មជជព** បណ្ដុះបណ្ដាលបច្ចេកទេសការងារ ចូលរចនាសម្ព័ន្ធក្នុងសហគមន៍ ។
- កម្មវិធី/គ្រោងការរបស់ **មជជព** ដឹកនាំបង្ហឹកការងារផ្ទាល់ ដើម្បីយកចំណេះដឹងទៅអនុវត្តន៍ ក្នុងរចនាសម្ព័ន្ធដែលបានបង្កើតរួចហើយ ។
- រចនាសម្ព័ន្ធដែលបានបង្កើតរួច ត្រូវអនុវត្តន៍សកម្មភាពបន្តដោយខ្លួនឯង ។

ឆ្នាំទី៣:

- ណែនាំដើម្បីឱ្យរចនាសម្ព័ន្ធនៅក្នុងសហគមន៍ ចេះគ្រប់គ្រង រៀបចំផែនការ និងស្វែងរកប្រភពហិរញ្ញវត្ថុដោយខ្លួនឯង ។
- **មជជព** ក្លាយជាអ្នកប្រឹក្សា និងជាទីប្រឹក្សា ទៅលើសកម្មភាពដែលបានដឹកនាំអនុវត្តន៍ ឆ្នាំទី១ ទី២ កន្លងមក ។
- **មជជព** ធ្វើការវាយតម្លៃ និងធ្វើសេចក្ដីសម្រេចចិត្ត ។

ឆ្នាំទី ៤ និង ទី ៥:

- ក្នុងករណីលទ្ធផលនៃការវាយតម្លៃរបស់ **មជជព** ទៅលើសហគមន៍ដែលបានបោះទីតាំង រួចហើយមិនទាន់មានស្ថេរភាព ឬនិរន្តរភាព **មជជព** អាចប្រើប្រាស់រយៈពេល ២ឆ្នាំនេះបន្ថែម ដើម្បីធ្វើទំនើបកម្មទៅលើចំណេះដឹង និងចំណេះធ្វើ ឬត្រួតពិនិត្យម្ដងម្កាល ។

សំគាល់:

ដើម្បីឱ្យបានទទួលជោគជ័យក្នុងឆ្នាំនីមួយៗ សូមមើលឧបសម្ព័ន្ធជាឧទាហរណ៍ ទៅតាមបទពិសោធន៍របស់ កម្មវិធី និងគ្រោងការ ដែលធ្លាប់ទទួលបានជោគជ័យ ។

**ប្រការ ៣:** និតិវិធីក្នុងការប្រគល់ និងទទួល

**មជឧព** ត្រូវជូនដំណឹងដល់សហគមន៍ ( តាមពិធីការរបស់ **មជឧព**) អំពីរយៈពេលដែលកម្មវិធីរបស់ខ្លួនត្រូវបោះទីតាំង និងត្រៀមលក្ខណៈទទួល និងផ្ទេរ ជូនសហគមន៍ទាំងស្រុងដើម្បីគ្រប់គ្រង ។

- *ពិធីផ្ទេរ* : **មជឧព** ត្រូវរៀបចំឯកសារទាំងឡាយណាដែលពាក់ព័ន្ធ ដូចជា:
  គំរូផែនការសកម្មភាពចុងក្រោយ, របាយការណ៍វាយតម្លៃ និងលិខិតផ្ទេរ ដែលត្រូវចុះហត្ថលេខា ។ **មជឧព** ត្រូវជូនដំណឹងដល់សហគមន៍ និងរចនាសម្ព័ន្ធ ដែលត្រូវទទួលយកយ៉ាងតិច ពី ៣ខែ ទៅ ៦ខែ អំពីការផ្ទេរនេះ ។ ការជូន ដំណឹងនេះ ត្រូវធ្វើឡើងនៅក្នុងឆ្នាំទី៣នៃការអនុវត្តន៍សកម្មភាព ។
- *ពិធីទទួល* : សហគមន៍ និងរចនាសម្ព័ន្ធដែលត្រូវទទួលយកត្រូវរក្សាទុក និង យកទៅអនុវត្តនូវឯកសារទាំងឡាយណាដែលបានផ្ទេរជូន ។ សហគមន៍ និងរចនាសម្ព័ន្ធ ដែលត្រូវទទួលយកត្រូវត្រៀមលក្ខណៈដើម្បីបន្តវេនធ្វើសកម្មភាព ដោយខ្លួនឯងយ៉ាងតិចរយៈពេលមួយឆ្នាំ មុនពេលការផ្ទេរជូន ។ ការទទួលយក នេះត្រូវធ្វើឡើងនៅក្នុងចុងឆ្នាំទី៣ ជាកំហិត ។

សំគាល់:

ទាំងការបោះទីតាំង ការផ្ទេរ និងការទទួល ត្រូវអនុវត្តទៅតាមពិធីការរបស់ **មជឧព** ។ សមាសភាពដែលចូលរួមមាន: ជនពិការ, តំណាង **មជឧព**, តំណាងអង្គការជាដៃគូរ រចនាសម្ព័ន្ធដែលត្រូវទទួលយក អាជ្ញាធរមូលដ្ឋាន និងតំណាងមន្ទីរ ក្រសួងដែលពាក់ព័ន្ធ ។

## ជំពូក ២

## អវសានបញ្ញត្តិ

**ប្រការ ៤:** ការបាត់បង់សុពលភាពរបស់គំរោង ឬគ្រោងការ និងរចនាសម្ព័ន្ធដែលត្រូវទទួលយកលុះត្រាតែ:

- អស្ថេរភាពមូលនិធិ
- កង្វះខាតធនធានមនុស្ស
- ជនពិការលែងត្រូវការសេវាកម្មបន្តទៀត
- គ្រោះមហន្តរាយធម្មជាតិ ឬ មានព្យុះសនកម្ម

- ការបង្វែរទិសដៅទៅបម្រើសកម្មភាព ដោយប្រាសចាកពីគោលបំណង មានជាអាទិ: ការចូលរួមក្នុងនិន្នាការនយោបាយគណៈបក្ស, សង្គ្រាម, សាសនា, ការកេងប្រវ័ញ្ចផលប្រយោជន៏រួម របស់អ្នកទទួលផល និងម្ចាស់ជំនួយ និងរាល់អំពើទាំងឡាយណាដែលផ្ទុយនិងច្បាប់រដ្ឋ ។

**ប្រការ ៥:** ការចូលជាធរមាន

គោលការណ៏នេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា និងប្រថាប់ត្រារបស់ មជជព។ គោលការណ៏នេះត្រូវបានចម្លងជូនដល់ភាគី ដែលពាក់ពន្ធ័ ដើម្បីជូនជ្រាបជាពតិមាន និងអនុវត្តន៏ ។

ភ្នំពេញ, ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៨

**យី ទាសនា**

**នាយកប្រតិបត្តិ មជជព**